**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 16-Feb-2012, 15:57
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំធ្វើសវនាការលើឯកសារបន្ថែម

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក គង់ សំអុន
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

**១-** បន្ទាប់ពីសវនាការលើឯកសារ ដែលបានធ្វើឡើងនៅថ្ងៃទី១៦ ដល់ ១៩ ខែមករា ឆ្នាំ២០១២ និងនៅថ្ងៃទី ១៣ ដល់ ១៦ ខែកុម្ភៈ ឆ្នាំ២០១២ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូង កំណត់ពេលវេលាសម្រាប់សវនាការលើឯកសារបន្ថែម ក្នុងឱកាសមួយឲ្យបានឆាប់បំផុត ដែលត្រូវចាប់ផ្តើមក្នុងអម្លុងពេលនៃវគ្គសវនាការបន្ទាប់។ ជាពិសេស សហព្រះរាជអាជ្ញាសូមស្នើឲ្យមានៈ

ក. សវនាការមួយ អនុលោមតាមវិធាន៨៧ (២) និង(៣) ស្តីពីភាពអាចទទួលយកបាននៃឯកសារដែលបានចុះបញ្ជីក្នុង **ឧបសម្ព័ន្ធ ៦-២០** នៃបញ្ជីឯកសារដំណាក់កាលដំបូងរបស់សហព្រះរាជអាជ្ញា[1] និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត។ សហព្រះរាជអាជ្ញាសូមស្នើថា សវនាការនេះកើតឡើងនៅក្នុងអម្លុងពេលពីរសប្តាហ៍ដំបូងនៃវគ្គសវនាការបន្ទាប់។ បើតាមជម្រើសផ្សេងពីនេះ បើសិនជាជនជាប់ចោទណាម្នាក់សម្រេចថា ខ្លួននឹងឆ្លើយបំភ្លឺអំពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារនៅពេលព្រឹក សហព្រះរាជអាជ្ញាសូមស្នើថា សវនាការធ្វើឡើងនៅក្នុងពេលរសៀលនៃសប្តាហ៍ទីមួយនៃសវនាការ និងបន្តរហូតដល់ចប់; ហើយនិង

ខ. សវនាការមួយសម្រាប់ការបង្ហាញភស្តុតាងទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ ដែលនឹងកើតឡើងនៅមុនពេលអនុញ្ញាតឲ្យជនជាប់ចោទបំភ្លឺនៅលើប្រធានបទនៃសវនាការមួយផ្សេងទៀត។

**២-** សវនាការទាំងនេះនឹងធ្វើឡើងតាមកិច្ចដំណើរការរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានអនុម័ត ទាក់ទងនឹងការប្រើប្រាស់ភស្តុតាងឯកសារនៅពេលជំនុំជម្រះ។ ក្រោមកិច្ចដំណើរការនេះ គូភាគីនានាទទួលបានឱកាសក្នុងការធ្វើអំណះអំណាងជំទាស់ទាក់ទងនឹងឯកសារដែលបានស្នើឡើង ដើម្បីដាក់បញ្ចូលជាភស្តុតាង។ គូភាគីក៏ត្រូវបានផ្តល់នូវឱកាសក្នុងការបង្ហាញភស្តុតាងផ្សេងៗ ដែលពួកគាត់

[1] **E109/4** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងដំណាក់កាលដំបូងនៃសវនាការ, ២២ កក្កដា ២០១១។

គិតថា មានសារសំខាន់ជាស្នូល និងមានភាពពាក់ព័ន្ធទៅនឹងប្រធានបទនៃការជំនុំជម្រះ ដែលក្នុងនោះសក្ខីកម្មរបស់ជនជាប់ចោទត្រូវបានស្តាប់រួចហើយ។

៣- ដើម្បីជាប្រយោជន៍ដល់ការអនុញ្ញាតដល់គូភាគីទាំងអស់ នូវពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំ សហព្រះរាជអាជ្ញាសូមស្នើថា សេចក្តីសម្រេចមួយទៅលើកថាខ័ណ្ឌ(១.ក)ខាងលើ គួរបានធ្វើនៅថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ២០១២នេះ។ ដើម្បីអនុញ្ញាតឲ្យបញ្ហានេះត្រូវបានសម្រេចឲ្យបានឆាប់ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះឲ្យមានចម្លើយតបដោយសង្ខេបពីគូភាគីដទៃទៀតនៅលើបញ្ហានេះ ។

## II. **សវនាការស្តីពីភាពអាចទទួលយកបាននៃឯកសារ**

៤- សវនាការកាលពីថ្ងៃទី១៦ ដល់១៩ ខែមករា ឆ្នាំ២០១២ បានផ្តល់ឱកាសដល់ភាគីនានា ដើម្បីឲ្យធ្វើការបង្ហាញនូវការជំទាស់ និងចម្លើយតបនានា ទៅនឹងឯកសារទាំងឡាយដែលបានលើកឡើងសំអាងដូចមាននៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងប្រធានបទនៃសវនាការលើកដំបូង(ប្រវត្តិដើម) ហើយនឹងឯកសារនានាដែលនៅក្នុង**ឧបសម្ព័ន្ធពីទី១ ដល់ទី៥** នៃបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសំរាប់សវនាការវគ្គដំបូង។ នៅក្នុងសេចក្តីសម្រេចពីការកំណត់ថ្ងៃសវនាការរបស់ខ្លួនដើម្បីស្តាប់អំពីប្រធានបទនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាការលើកសំអាងដោយផ្ទាល់មាត់បន្ថែមនឹងត្រូវបានកំណត់កាលវិភាគទាក់ទងជាមួយនឹងឯកសារផ្សេងៗទៀតដែលនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសំរាប់សវនាការវគ្គដំបូង ក្នុងខែកុម្ភៈ ឆ្នាំ២០១២[2]។ ការលើកសំអាងនេះត្រូវបានកំណត់កាលវិភាគជាបណ្តោះអាសន្នដើម្បីគ្រោងធ្វើនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ដែលទាក់ទងជាមួយនឹងឧបសម្ព័ន្ធទី៨ និងទី១៧[3]។ ក៏ប៉ុន្តែដោយពិចារណាអំពីពេលវេលា សវនាការនេះត្រូវបានបង្ខំត្រូវតែលើកពេល។

---

[2] ឯកសារលេខ **E159** ការកំណត់កាលបរិច្ឆេទនៃការធ្វើសវនាការដោយផ្ទាល់មាត់ស្តីពីឯកសារនានា (ពីថ្ងៃទី១៦-១៩ មករា ២០១២), ថ្ងៃទី១១ មករា ២០១២ ត្រង់កថាខណ្ឌទី៩។

[3] ឯកសារលេខ **E170** ការកំណត់កាលបរិច្ឆេទនៃការធ្វើសវនាការដោយផ្ទាល់មាត់ស្តីពីឯកសារនានា (ពីថ្ងៃទី១៣-១៥ មករា ២០១២), ថ្ងៃទី០៩ មករា ២០១២ ត្រង់កថាខណ្ឌទី៨។

**៥-** សូមជូនសេចក្តីសន្និដ្ឋានថា ដើម្បីជាផលប្រយោជន៍ដល់ការគ្រប់គ្រងសវនាការ គួរបានបំពេញសវនាការឱ្យបានចប់សព្វគ្រប់ស្តីពីភាពអាចទទួលយកបាននៃឯកសារដែលនៅសេសសល់ *ទាំងអស់* ដែលបានស្នើសុំដោយភាគីនានា នៅក្នុងឱកាសដ៏ឆាប់បំផុត។ ដូចដែលបានធ្វើការកត់សំគាល់រួចហើយនៅក្នុងការដាក់ឯកសារលើកមុនៗ ការដោះស្រាយអំពីភាពអាចទទួលយកបាននៃឯកសារបានឆាប់ នឹងជួយធ្វើឱ្យដំណើរការនីតិវិធីបានលឿន ដែលអនុញ្ញាតឱ្យភាគីនានាបង្ហាញជូននូវឯកសារនានាដល់សាក្សីបានដោយប្រសិទ្ធភាពនៅក្នុងពេលធ្វើសវនាការលើអង្គសេចក្តីដោយពុំមានការអាក់ខានដោយសារការលើកឡើងនូវសំអាងផ្សេងៗដែលទាក់ទងនឹងអង្គច្បាប់[4]។ ការធ្វើដូចនេះ ក៏នឹងអនុញ្ញាតផងដែរឱ្យភាគីនានាដើម្បីធ្វើសេចក្តីសន្និដ្ឋានជូនទៅអង្គជំនុំជំម្រះសាលាដំបូង ដូចជា អំពីចំនួនសាក្សីដែលតម្រូវឱ្យធ្វើការកោះហៅសំរាប់សវនាការដែលនឹងត្រូវធ្វើជាបន្តទៅទៀត។ រហូតទល់ពេលដែលសេចក្តីសំរេចស្តីពីភាពអាចទទួលយកបាននៃរាល់ឯកសារទាំងអស់ដែលនៅក្នុង**ឧបសម្ព័ន្ធពីទី១ដល់ទី២០** នៃបញ្ជីឯកសារសំរាប់សវនាការវគ្គដំបូងរបស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីនានាត្រូវបានចេញ គឺភាគីទាំងនេះមានការលំបាកយ៉ាងខ្លាំងជាទីបំផុតនៅក្នុងការផ្តល់នូវការវាយតម្លៃឱ្យបានត្រឹមត្រូវមួយជូនអង្គជំនុំជម្រះសាលាដំបូងអំពីថា តើគួរតម្រូវឱ្យមានចំនួនសាក្សីតិច ឬច្រើនជាងនេះ ដើម្បីបំពេញឱ្យបានគ្រប់តាមកាតព្វកិច្ចរបស់ពួកគេ នៅក្នុងសវនាការនេះ។

**៦-** ហេតុដូចនេះ សហព្រះរាជអាជ្ញាសូមស្នើថា មុនពេលធ្វើសវនាការលើភស្តុតាងសក្ខីកម្មជាបន្ថែមទៀត រយៈពេលពីរសប្តាហ៍ដំបូងនៃសវនាការលើកបន្ទាប់នេះគឺថា ពីថ្ងៃទី១២ ដល់ ថ្ងៃទី២២ ខែមីនាឆ្នាំ ២០១២ គួរត្រូវបានទុកសំរាប់តែធ្វើសវនាការលើ**ឧបសម្ព័ន្ធពីទី៦ ដល់ទី២០** នៃបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាជាបន្ថែមពីលើឯកសារនានាដែលបានស្នើសុំដោយភាគីផ្សេងៗទៀតប៉ុណ្ណោះបានហើយ។ ជាជំរើសមួយទៀតផ្សេងពីនេះ បើសិនជាជនជាប់ចោទណាម្នាក់សំរេចចិត្តថានឹងផ្តល់សក្ខីកម្មនៅ

[4] ឯកសារលេខ **E136** សំណើរបស់សហព្រះរាជអាជ្ញាសុំបង្កើតនូវប្រព័ន្ធដ៏មានប្រសិទ្ធភាពមួយសំរាប់ការទទួលយកនូវឯកសារភស្តុតាងនៅក្នុងសវនាការ, ចុះថ្ងៃទី៣ វិច្ឆិកា ២០១១ និង ឯកសារលេខ E153 សំណើរបស់សហព្រះរាជអាជ្ញា ស្តីពីការគ្រប់គ្រងសវនាការ, ចុះថ្ងៃទី៤ ធ្នូ ២០១១។

ក្នុងពេលសវនាការនៅពេលព្រឹកលើប្រធានបទស្តីពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារនោះ សូមស្នើឱ្យអង្គសវនាការទាំងនេះធ្វើឡើងនៅពេលរសៀលនៃសប្តាហ៍ដំបូងៗនៅក្នុងសវនាការលើកក្រោយបន្ទាប់ពីនេះ ហើយសូមឱ្យធ្វើជាបន្តទៀតរហូតដល់ចប់សព្វគ្រប់។

**៧-** សូមជូនសេចក្តីសន្និដ្ឋានថា ការកំណត់ពេលវេលាក្នុងការធ្វើសវនាការទាំងនេះ និងសេចក្តីសំរេចដំបូងៗស្តីពីភាពអាចទទួលយកបាននៃឯកសារនានាទំនងជានឹងជួយកាត់បន្ថយយ៉ាងច្រើននូវរយៈពេលនៃការធ្វើសវនាការនេះ។

## III. សវនាការស្តីពីការបង្ហាញឯកសារជាសាធារណៈ

**៨-** នៅក្នុងអំឡុងពេលសវនាការកាលពីថ្ងៃទី១៣ ដល់ ១៦ ខែកុម្ភៈ ឆ្នាំ២០១២ ភាគីនានាត្រូវបានផ្តល់នូវកាលានុវត្តភាពក្នុងការបង្ហាញឯកសារមួយចំនួនដែលមានកម្រិត ដែលត្រូវបានពិចារណាថាមានការទាក់ទងជាក់លាក់ទៅនឹងផ្នែកប្រវត្តិសាស្ត្រនៃសម័យកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាគោលបំណងនៃសវនាការនេះគឺ៖

> *ធ្វើយ៉ាងណាឱ្យសាធារណៈជនទទួលបានព័ត៌មានកាន់តែទូលំទូលាយ និងផ្តល់ឱកាសដល់ភាគីស្នើសុំដើម្បីបង្ហាញអង្គជំនុំជម្រះនូវឯកសារមួយចំនួនដែលភាគីយល់ថា ជាឯកសារសំខាន់សម្រាប់សវនាការវគ្គដំបូងស្តីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាក្នុងសំណុំរឿង ០០២/០១ នេះ*[5]។

**៩-** សហព្រះរាជអាជ្ញា បានពិចារណាថា សវនាការលើឯកសារនេះ មានប្រសិទ្ធិភាពនៅក្នុងការដែលបានត្រូវទៅតាមគោលបំណងនេះ និងជំរុញការកំណត់កាលបរិច្ឆេទធ្វើសវនាការបែបនេះភ្លាមនៅមុនជនជាប់ចោទត្រូវបានស្នើឱ្យផ្តល់សក្ខីកម្មលើប្រធានបទសវនាការក្រោយ។ សហព្រះរាជអាជ្ញាបានកត់

---

[5] **E170** ការកំណត់កាលបរិច្ឆេទសនៃវនាការផ្ទាល់មាត់លើឯកសារ (១៣-១៥ កុម្ភៈ ២០១២), ០៩ កុម្ភៈ ២០១២ ត្រង់កថាខណ្ឌទី២៖ "ដូចដែលបានបញ្ជាក់កាលពីពេលមុន អង្គជំនុំជម្រះមានបំណងផ្តល់ឱកាសដល់ភាគីដើម្បីបង្ហាញឯកសារមួយចំនួនតូច ដែលភាគីយល់ថាជាឯកសារពាក់ព័ន្ធទៅនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាដែលជាវគ្គដំបូងនៃសវនាការលើសំណុំរឿង០០២/០១។ សវនាការនេះមានគោលបំណងធ្វើយ៉ាងណានៅពេលភាគីលើកឯកសារណាមួយ ជនជាប់ចោទមានសិទ្ធិធ្វើអត្ថាធិប្បាយលើឯកសារនោះ ប្រសិនបើជនជាប់ចោទមានបំណងធ្វើដូច្នេះ" កថាខណ្ឌទី២។

សម្គាល់ថា មន្ត្រីច្បាប់ជាន់ខ្ពស់ធ្លាប់បានបញ្ជាក់រួចហើយថា អង្គជំនុំជម្រះសាលាដំបូងនឹងយកចិត្តទុកដាក់តាមដានលើវិធីសាស្ត្រនេះ[6]។ យោងទៅតាមនេះ ដោយហេតុថា ខ្លួនបានរៀបចំកាលបរិច្ឆេទសម្រាប់ប្រធានបទសវនាការបន្ទាប់នេះ (រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ) សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើបញ្ញត្តិសម្រាប់សវនាការក្រោយមួយនៅក្នុងអំឡុងពេលដែលភាគីនានាអាចបង្ហាញឯកសារសំខាន់ៗរបស់ខ្លួន ដែលទាក់ទងទៅនឹងប្រធានបទនោះ។

## IV. ដំណោះស្រាយដែលបានស្នើសុំ

**១០-** ចំពោះហេតុផលដូចខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់កាលបរិច្ឆេទឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន (ហើយទាក់ទងទៅនឹងកថាខណ្ឌ(ក) ខាងក្រោម នៅមុន ឬ នៅថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ២០១២)៖

(ក) សវនាការមួយស្ដីពីការទទួលយកបានឯកសារនានា ដែលបានចុះជាបញ្ជីនៅក្នុង**ឧបសម្ព័ន្ធ ៦-២០** នៃបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការវគ្គដំបូង និង ឯកសារនានាដែលបានស្នើដោយភាគីនានា ដែលសវនាការនេះនឹងត្រូវធ្វើឡើងនៅក្នុងអំឡុងពេលពីរសប្ដាហ៍ដំបូងនៃសវនាការវគ្គបន្ទាប់នេះ គឺពីថ្ងៃទី ១២ ដល់ ២២ ខែមីនា ឆ្នាំ២០១២ ឬមួយក៏ម្យ៉ាងវិញទៀត បើជនជាប់ចោទសម្រេចចិត្តផ្ដល់សក្ខីកម្មលើ រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ ត្រូវធ្វើឡើងនៅក្នុងអំឡុងវគ្គពេលរសៀលនៃសប្ដាហ៍ដំបូងៗនៃសវនាការរហូតដល់ភាគីនានាបានស្ដាប់ឯកសារទាំងអស់នោះ។ និង

(ខ) សវនាការមួយសម្រាប់ធ្វើការបង្ហាញឯកសារសំខាន់ៗទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ ដែលសវនាការនេះនឹងត្រូវធ្វើឡើងនៅមុនពេលដែលជនជាប់ចោទត្រូវបានអញ្ជើញឲ្យផ្ដល់សក្ខីកម្មលើប្រធានបទសវនាការមួយផ្សេងទៀត៕

[6] **E167.1** អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់, សារជូនដល់ភាគីនានាជាមុនស្ដីពីការប្រជុំការគ្រប់គ្រងសវនាការ (TMM) ក្រៅផ្លូវការនៅព្រឹកថ្ងៃស្អែក, ២ កុម្ភៈ ២០១២ បានថ្លែងថា៖ "វាជាការមានប្រយោជន៍សម្រាប់អង្គជំនុំជម្រះ (នៅពេលធ្វើសេចក្ដីសន្និដ្ឋានលើវគ្គទីមួយនៃសវនាការ) ដើម្បីឲ្យបានទទួលនូវការបញ្ជាក់ដ៏ច្បាស់លាស់មួយពីភាគីនានាស្ដីពីឯកសារមួយចំនួនតូច (ដាក់បន្ទុក និង ដោះបន្ទុក) ដែលភាគីនីមួយៗបានពិចារណាថាមានភាពទាក់ទងយ៉ាងជាក់លាក់ពាក់ព័ន្ធទៅនឹងផ្នែកសវនាការដែលជិតនឹងបញ្ចប់ទៅនេះ"។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |